# <ព័ត៌មាន អំពីប្រតិកម្មមិនល្អ បន្ទាប់ពីចាក់វ៉ាក់សាំង> (캄보디아어)

**ក្នុងករណីនេះ សូមធ្វើតាមការណែនាំ។**

. ក្រោយពេលចាក់វ៉ាក់សាំងហើយ ករណី ឈឺ ឬហើមកន្លែងចាក់នោះ
សូមស្អំត្រជាក់ដោយរុំជាមួយកន្សែងស្ងួតស្អាត។

. ក្រោយពេលចាក់វ៉ាក់សាំងហើយ ករណីមានកំដៅ សូមបរិភាគទឹកអោយបានគ្រប់គ្រាន់ និងសម្រាក។

. ក្រោយពេលចាក់វ៉ាក់សាំងហើយ ក្នុងករណីមិនស្រួលខ្លួន ដោយសារមានកំដៅ ឬឈឺសាច់ដុំគឺ អាចជួយអ្នក
បានប្រសិនបើអ្នក បរិភាគថ្នាំបញ្ចុះកំដៅ ឬថ្នាំបំបាត់ការឈឺចាប់។

* មុននឹងធ្វើការចាក់វ៉ាក់សាំង សូមត្រៀមជាមុននូវថ្នាំបញ្ចុះកំដៅ និងថ្នាំបំបាត់ការឈឺចាប់ដែលមានផ្ទុកសារធាតុ
អាសេតោមីណូហ្វេនេ, ក្រោយចាក់វ៉ាក់សាំងហើយ ប្រសិនបើមានអាការៈឈឺខ្លួន សូមបរិភាគថ្នាំបញ្ចុះកំដៅ
និងថ្នាំបំបាត់ ការឈឺចាប់។

**ក្នុងករណីនេះ សូមទៅទទួល ព្យាបាលពី វេជ្ជបណ្ឌិត។**

. ក្រោយពេលចាក់វ៉ាក់សាំងហើយ ករណីមានហើម, ឈឺ, ទ្បឹងក្រហម នៅកន្លែងចាក់ មិនអាចប្រសើរឡើង
លើសពី៤៨ម៉ោង

. ក្រោយពេលចាក់វ៉ាក់សាំងហើយ ករណីបានលចេឡើងនូវអាការៈ ដូចជាពិបាកដកដង្ហើម, ឈឺទ្រូង,
ឈឺពោះជាប់រហូត, និង ហើមជើង ក្នុងរយៈពេល៤សប្តាហ៍

. ក្រោយពេលចាក់វ៉ាក់សាំងហើយ ប្រសិនបីកីតឡើងនូវការឈឺក្បាលខ្លាំងជាប់រហូត ឬលើសពី២ថ្ងៃ,
ករណីថ្នាំបំបាត់ការឈឺចាប់មិនមានប្រសិទ្ធភាពឬ មិនអាចសម្រួលបាន ឬក៏មានករណីស្រវាំងភ្នែក

. ក្រោយពេលចាក់វ៉ាក់សាំងហើយ ករណីបានលចេឡើងនូវអាការៈអស់កំលាំងភ្លាមៗ
ឬខុសប្លែកពីអាការៈធម្មតា

. ក្រោយពេលចាក់វ៉ាក់សាំងហើយ ករណីមានស្នាមជាំ ឬចញ្ចេញឈាម នៅកន្លែង ដលែមិនមនែចាក់វ៉ាក់សាំង

**ក្នុងករណីនេះ សូមរាយការណ៍ទៅលេខ ១១៩ ឬទៅមន្ទីរពេទ្យ បន្ទប់សង្គ្រោះបន្ទាន់។**

. ក្រោយពេលចាក់វ៉ាក់សាំងហើយ ករណីពិបាកក្នុងការដកដង្ហើម ឬវិលមុខខ្លាំង

. ក្រោយពេលចាក់វ៉ាក់សាំងហើយ ករណីមានលចេឡើងនូវ ការហើមបបូរមាត់, មុខ ឬអាការៈ
ចញ្ចេកន្ទួលខ្លាំងពេញខ្លួន

. ក្រោយពេលចាក់វ៉ាក់សាំងហើយ ករណី សន្លប់ ឬដួល ភ្លាមៗ

< បកប្រែដោយមជ្ឈមណ្ឌលប្រឹក្សាតាមទូរស័ព្ទដានូរី ១៥៧៧ - ១៣៦៦ >